**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ថ្ងៃពុធ ២រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
## ការរៀបចំសន្និសីទសារព័ត៌មាន
## ស្តីពី «ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣»

**ក្រសួងមុខងារសាធារណៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** មានកិត្តិយសសូមជម្រាបសាធារណជន និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ ជ្រាបថា៖ ដំណើរការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ចំនួន ២៥០នាក់ សម្រាប់ឆ្នាំ២០២៣ បាន និងកំពុងដំណើរការ បន្ទាប់ពីគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ បានប្រកាសបើកទទួលពាក្យជាផ្លូវការកាលពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ។ ក្នុងគោលបំណងដើម្បីផ្តល់វឌ្ឍនភាពព័ត៌មានអំពីដំណើរការរៀបចំ និងនិតិវិធី ឆ្ពោះទៅកាន់ការប្រឡងជ្រើសរើសមន្ត្រីកសិកម្មឃុំជូនបេក្ខជន និងសាធារណជន **ក្រសួងមុខងារសាធារណៈ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** នឹងសហការរៀបចំសន្និសីទសារព័ត៌មានស្តីពី «**ការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំឆ្នាំ២០២៣**» ដែលសន្និសីទសារព័ត៌មាននេះ នឹងប្រព្រឹត្តទៅដូចខាងក្រោម៖

| | |
|---|---|
| **កាលបរិច្ឆេទ៖** | ថ្ងៃចន្ទ ៧រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧<br>ត្រូវនឹងថ្ងៃចន្ទ ទី៤ ខែធ្នូ ឆ្នាំ២០២៣ |
| **ពេលវេលា និងទីតាំង៖** | វេលាម៉ោង ៣រសៀល, នៅសាលាភូមិន្ទរដ្ឋបាល |
| **គណៈអធិបតី៖** | **ឯកឧត្តម ហ៊ុន ម៉ានី** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានគណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ ឆ្នាំ២០២៣<br>**ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ ជ្រាបជាព័ត៌មាន។ សម្រាប់ព័ត៌មានបន្ថែម និងការចុះឈ្មោះចូលរួមយកព័ត៌មាន សូមទាក់ទងតាមរយៈ លោកស្រី ជារ៉េត រ៉ូហ្សាលីន (០៨១ ៨២០ ០៨១) ឬ លោកស្រី រស់ ស៊ីណាក់ (០១២ ៥៥៣ ១១៥)។

សូមអរគុណ!